មាត្រា ២.- រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី និងមេបញ្ជាការកងឯកភាពអង្គរក្សសម្តេច ហ៊ុន សែន ត្រូវអនុវត្តអនុក្រឹត្យនេះ អោយបានទទួលលទ្ធផលល្អ ។

រាជធានីភ្នំពេញ, ថ្ងៃទី ២២ ខែ សីហា ឆ្នាំ ២០០០

នាយករដ្ឋមន្ត្រី

ហត្ថលេខា និងត្រា

ហ៊ុន សែន

★★★

## ២-សេចក្តីណែនាំ

រាជធានីភ្នំពេញ, ថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០០

### សេចក្តីណែនាំលេខ ០៩ សណន
### ស្តីពីការធានាសណ្តាប់ធ្នាប់ និងសុវត្ថិភាពនៅក្នុងស្ថានីយ៍
### នៃព្រលានយន្តហោះអន្តរជាតិពោធិចិនតុង និងសៀមរាប

***

ដោយពិនិត្យឃើញថា ក្នុងស្ថានីយ៍នៃព្រលានយន្តហោះអន្តរជាតិពោធិចិនតុង និងសៀមរាប ស្ថិតក្នុងស្ថានភាពបាត់សណ្តាប់ធ្នាប់ ព្រោះការចេញ- ចូលនៅតាមតំបន់នានា ក្នុងស្ថានីយ៍មានភាពច្របូកច្របល់ទាំងអាជ្ញាធរទាំងសមត្ថកិច្ច ពាក់ព័ន្ធជាមួយអ្នកដំណើរ អ្នកជូនដំណើរផង ដែលជាបញ្ហាបង្កនូវការលំបាកដល់ការកិច្ចរបស់អាជ្ញាធរមានសមត្ថកិច្ចក្នុងស្ថានីយ៍ ហើយក៏ជះឥទ្ធិពលមិនល្អដល់កិត្យានុភាពជាតិ និងនាំអោយរាំងស្ទះការធានាសន្តិសុខសុវត្ថិភាពរបស់ស្ថានីយ៍ រាជរដ្ឋាភិបាលដាក់ចេញនូវសេចក្តីណែនាំដល់អាជ្ញាធរមានសមត្ថកិច្ចនៅព្រលានយន្តហោះអន្តរជាតិ ដូចខាងក្រោម :

១-<u>តំបន់សាធារណៈ</u>

គឺជាតំបន់ចំណតរថយន្ត និងទីធ្លាសំរាប់អ្នកដំណើរ អ្នកជូន អ្នកទទួល អ្នកបើកបររថយន្តសំរាករង់ចាំ ។

២-<u>តំបន់សមត្ថកិច្ច</u> :

រួមមាន :

-បន្ទប់បំពេញបែបបទចេញដំណើរ

-បន្ទប់រង់ចាំចេញដំណើរ

-បន្ទប់បំពេញបែបបទចូលប្រទេស

-បន្ទប់បំពេញបែបបទសំរាប់ជើងយន្តហោះក្នុងស្រុក

-ទីលានយន្តហោះចុះចត

-កន្លែងអ្នកដំណើរចេញ -ចូលបំពេញបែបបទនៃការធ្វើដំណើរ

-កន្លែងអាជ្ញាធរមានសមត្ថកិច្ចនៅច្រកទ្វារព្រំដែន ដែលត្រូវធ្វើបែបបទអោយអ្នកដំណើរ

-កន្លែងភ្នាក់ងារសន្តិសុខដែលមានភារកិច្ចរៀបចំសពីវ៉ាប់ផ្ញើ

-កន្លែងបុគ្គលិកក្រុមហ៊ុនយន្តហោះដែលត្រូវធ្វើបែបបទអោយអ្នកដំណើរ

-កន្លែងក្រុមហោនិក ក្រុមអ្នកបច្ចេកទេសយន្តហោះ ដែលបំរើការក្នុងផែនហោះហើរនីមួយៗ

-កន្លែងបុគ្គលិកលក់ទំនិញនៅស្ថានីយ៍ ដែលមានការទទួលស្គាល់ពីអាជ្ញាធរអាកាសចរស៊ីវិល ។

ចាប់ពីពេលនេះតទៅ មិនអនុញ្ញាតអោយអ្នកគ្មានសមត្ថកិច្ចចេញ -ចូល តំបន់នេះឡើយ ដោយគ្មានករណីលើកលែង និងគ្មានករណីពិសេស ។ ចំពោះទីតាំងតំណាងសណ្ឋាគារសំរាប់ទទួលភ្ញៀវរបស់ខ្លួនត្រូវរៀបចំនៅក្រៅតំបន់សមត្ថកិច្ច ។ ចំណែកមគ្គុទ្ទេសក៏ នៃក្រុមហ៊ុនទេសចរណ៍ អាចអនុញ្ញាតអោយចូលទទួលភ្ញៀវរបស់ខ្លួនត្រឹមពណ្ឌលក្រោយ បន្ទាប់ពីបែបបទរបស់សមត្ថកិច្ចគយ និងវដ្ឋាករ ។

៣-<u>តំបន់បន្ទប់ទទួលភ្ញៀវពិសេស</u> ( VIP ) :

-ត្រូវអនុវត្តអោយបានម៉ឹងម៉ាត់នូវលិខិតលេខ ១៥៨៥ សជណ.ផក ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ១៩៩៥ របស់ទីស្តីការគណៈរដ្ឋមន្ត្រី ស្តីពីការប្រើប្រាស់បន្ទប់ទទួលភ្ញៀវពិសេសនៅអាកាសយានដ្ឋានពោធិចិនតុង ។

ចំពោះសមាជិកព្រឹទ្ធសភា និងមន្ត្រីសង្ឃ មានងារជាសម្តេច ក៏ត្រូវបានអនុញ្ញាតអោយប្រើប្រាស់បន្ទប់ទទួលភ្ញៀវពិសេសនេះដែរ ។

ចំពោះការចេញ - ចូលរបស់គណៈប្រតិភូពិសេសជាន់ខ្ពស់ នឹងត្រូវបានរៀបចំដោយឡែកតាមករណីនីមួយៗ ។

ទទួលបានសេចក្តីណែនាំនេះ ឯកឧត្តមរដ្ឋមន្ត្រីនៃបណ្តាក្រសួង ស្ថាប័ន ដែលមានអង្គភាពក្រោមឱវាទ កំពុងបំពេញភារកិច្ចនៅព្រលានយន្តហោះអន្តរជាតិពោធិចិនតុង និងសៀមរាប ត្រូវចាត់ចែង អនុវត្តអោយមានប្រសិទ្ធិភាពខ្ពស់ ។

នាយករដ្ឋមន្ត្រីស្តីទី
ហេតុលេខា និងត្រា
ស ខេង

***